

ថ្ងៃមួយ លោកគ្រូសុខនិងខេទីកំពុងដើរទៅផ្សារ ដើម្បីទិញនំប៉ុង។
លោកគ្រូសុខបានប្រាប់ខេទី
« តើអ្នកមានដឹងអត់ កាលពីមុន ខ្ញុំធ្លាប់ធ្វើការនៅហាងនំប៉ុង »
« មែនឬ? » ខេទីសួរទាំងភ្ញាក់ផ្អើល។
« ខ្ញុំស្មានថាអ្នកជាគ្រូបង្រៀន តាំងពីដើមមកទេតើ »
« អត់ទេ » លោកគ្រូសុខឆ្លើយដោយញញឹម។
« កាលពីមុន ខ្ញុំធ្លាប់ធ្វើការងារផ្សេងៗជាច្រើនទៀត តែអ្នកមិនដឹង »។



« ដំបូងឡើយ ខ្ញុំបានទៅជួយអ្នកធ្វើនំប៉័ងម្នាក់។ ខ្ញុំចេះប្រើឧបករណ៍វឹកម្សៅ ឈើលុញម្សៅ ស្លាបព្រាឈើ ដើម្បីធ្វើនំប៉័ងនិងនំប៊ីស្គីត »។

ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »

« អូ! វាពិបាកជាងការដុតនំខេកញ៉ាំនៅឯផ្ទះឆ្ងាយណាស់។ ណាមួយ មកពីខ្ញុំចេះតែញ៉ាំវាច្រើនពេកហ្នឹងណ៎ា » គាត់និយាយទាំងសើច។



« បន្ទាប់មក ខ្ញុំបានទៅជួយជាងជួសជុលម៉ូតូម្នាក់ រហូតដល់ខ្ញុំចេះប្រើ
ទួរណឺវីស កូនសោរនិងញញួរ ដើម្បីជួសជុលម៉ូតូ »។
ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »
លោកគ្រូសុខឆ្លើយ « អូ! ការងារហ្នឹងវាពិបាកជាងសប់កង់ម៉ូតូខ្លួនឯងឆ្ងាយណាស់
ម៉្យាងវិញទៀត ស្នែងរបស់ខ្ញុំចេះតែជាប់កាំម៉ូតូទៀតផង » គាត់និយាយទាំងសើច។



« ក្រោយមកទៀត ខ្ញុំធ្លាប់ធ្វើជាជំនួយការគ្រូពេទ្យម្នាក់ រហូតដល់ខ្ញុំចេះរៀបចំបង់រុំរបួស ទែម៉ូម៉ែត្រនិងថ្នាំមួយចំនួនឱ្យគាត់ »។
ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »
« អូ! ការងារហ្នឹងពិបាកជាងទៅទិញថ្នាំនៅឯឱសថស្ថានឆ្ងាយណាស់។ ម៉្យាងវិញទៀត គ្រាន់តែឃើញគេចាក់ថ្នាំ ខ្ញុំចង់សន្លប់បាត់ទៅហើយ » គាត់និយាយហើយក៏សើច។



« បន្ទាប់មក ខ្ញុំបានទៅជួយជាងឈើម្នាក់ រហូតដល់ខ្ញុំចេះប្រើញញួរ
ដែកគោលនិងរណារ ដើម្បីធ្វើតុនិងទូ »។
ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »
« អូ! ការងារហ្នឹងពិបាកជាងជួសជុលកៅអីនៅផ្ទះខ្លួនឯងឆ្ងាយណាស់ »។
គាត់បន្តទាំងសើចក្អឹកៗ « ម៉្យាងវិញទៀត ខ្ញុំចេះតែឧស្សាហ៍ដំញញួរចំមេដៃខ្លួនឯង
ជាច្រើនដងពេក »។



« ក្រោយមក ខ្ញុំក៏បានទៅជួយអ្នកនេសាទត្រីម្នាក់វិញម្តង។ ខ្ញុំចេះចែវទូក ចេះបង់សំណាញ់ ចេះស្ទូចត្រីកាម៉ុងនិងត្រីតុកកែ »។
ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »
« អូ! ការងារហ្នឹងពិបាកជាងស្ទូចត្រីនៅតាមមាត់ទន្លេឆ្ងាយណាស់ »។
គាត់និយាយទាំងសើច « ហើយម៉្យាងទៀត ខ្ញុំចេះតែពុលទឹករលកមិនបាត់សោះ »។



« បន្ទាប់ពីនោះមក ខ្ញុំបានទៅជួយអ្នកធ្វើអំបិលម្នាក់។ ខ្ញុំចេះប្រើចបកាប់ រនាស់និងប៉ែល ដើម្បីប្រមូលអំបិល »។

ខេទីក៏សួរ « ហើយក្រោយមក មានរឿងអ្វីកើតឡើងទៅ? »

« អូ! ការងារហ្នឹងពិបាកជាងទៅផ្សារទិញអំបិលឆ្ងាយណាស់។ ណាមួយ វាធ្វើឱ្យរបួសរបស់ខ្ញុំក្រហាយមិនឈប់ទៀតផង » គាត់និយាយទាំងសើច។



« ក្រោយមក ខ្ញុំបានទៅជួយជាងកាត់ដេរម្នាក់។ ខ្ញុំចេះប្រើកន្ត្រៃ សម្រាប់កាត់ ម៉ែត្រសំពត់និងម៉ែត្រឈើ ឬ ឆៀកសម្រាប់វាស់ ម្ជុលសម្រាប់ខ្ទាស់និងដីសសម្រាប់គូសចំណាំលើក្រណាត់នៅកន្លែងដែលត្រូវកាត់ »។

ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »

« អូ! ការងារហ្នឹងពិបាកជាងដេរឡេវអាវខ្លួនឯងឆ្ងាយណាស់។ ហើយម៉្យាងទៀត ខ្ញុំតែងតែធ្វើឱ្យម្ជុលមុតដៃជាញឹកញាប់ទៀតផង » គាត់និយាយហើយក៏សើច។



« ខ្ញុំក៏ធ្លាប់បានទៅជួយជាងថតរូបម្នាក់ផងដែរ។ កាលនោះ ខ្ញុំចេះប្រើកាមេរ៉ា ប្រើភ្លើងនិងជើងទម្រ ដើម្បីថតរូប »។

ខេទីក៏សួរ « ហើយចុះក្រោយមក មានរឿងអ្វីកើតឡើងទៅ? »

« អូ! ការងារហ្នឹងពិបាកជាងថតរូបតាមទូរស័ព្ទដៃខ្លាំងណាស់។ ម៉្យាងវិញទៀត ខ្ញុំឧស្សាហ៍ថតរូបមិនច្បាស់ ដាច់ជើងឬដាច់ដៃរហូតហ្នឹង » គាត់និយាយហើយក៏សើច។



« បន្ទាប់មក មានថ្ងៃមួយ ខ្ញុំបានបង្រៀនក្មួយរបស់ខ្ញុំឱ្យធ្វើលំហាត់ កិច្ចការផ្ទះរហូតដល់ចប់ »។
ក្មួយខ្ញុំបាននិយាយ « លោកពូពិតជាពន្យល់មេរៀនបានល្អខ្លាំងណាស់ »។



« ដូច្នេះ ខ្ញុំក៏ទៅជួយគ្រូបង្រៀនម្នាក់ ហើយអ្វីដែលសំខាន់នោះគឺ ខ្ញុំមិនមានអារម្មណ៍ថា ការងារហ្នឹងពិបាកអីបន្តិចសោះ! បើនិយាយឱ្យពិតទៅ គឺខ្ញុំសប្បាយចិត្តនឹងធ្វើវាយ៉ាងខ្លាំង តែមិនមែនថា នរណាក៏អាចក្លាយជាជាងឈើ អ្នកធ្វើនំប៉័ង ឬ គ្រូបង្រៀនភ្លាមៗបាននោះទេ យើងត្រូវខំរៀនជាមុនសិន »។



‹‹ ខ្ញុំផ្ទាល់ក៏ត្រូវរៀនជាមុនសិនដែរ ខ្ញុំបានចូលរៀននៅថ្នាក់មហាវិទ្យាល័យ ហើយចាប់យកជំនាញគ្រូបង្រៀន ››។



« ជាការពិតណាស់ ការចាប់យកការងារដែលយើងស្រឡាញ់ វាមិនងាយស្រួលរហូតនោះទេ ដោយសារតែសង្គមយើងមានការងារជាច្រើនខុសៗគ្នាសម្រាប់ឱ្យយើងជ្រើសរើស។ សម្រាប់ខ្ញុំ រឿងដែលសំខាន់បំផុតនោះគឺ ខ្ញុំសប្បាយចិត្តនឹងធ្វើការងារនោះ »

តើការងារមួយណាដែលអ្នកគិតថា អ្នកចូលចិត្តធ្វើ?




# តើអ្នកចង់ធ្វើការងារអ្វី?

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary